**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ០៦ ប្រ.ក.ជា...

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩

នៅព្រឹកថ្ងៃពុធ ១៣កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើះ

**១-គម្រោងទិញថាមពលអគ្គិសនីពីរោងចក្រផលិតអគ្គិសនីដុតធ្យូងថ្ម អានុភាព២៤០០ មេហ្គាវ៉ាត់ នៅតំបន់រ៉ែធ្យូងថ្ម នៅខេត្តសេកុង សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។**

**២-បញ្ហាផ្សេងៗ៖**

សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើះ

២.១.កិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២.២.កិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការបង្កើតសម្ព័ន្ធភាពថាមពលព្រះអាទិត្យអន្តរជាតិ។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័តះ

**១-គម្រោងទិញថាមពលអគ្គិសនីពីរោងចក្រផលិតអគ្គិសនីដុតធ្យូងថ្ម អានុភាព២៤០០មេហ្គាវ៉ាត់ នៅតំបន់រ៉ែធ្យូងថ្ម នៅខេត្តសេកុង សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

សន្តិភាពនិងស្ថិរភាពនយោបាយនៅកម្ពុជា បាននាំមកនូវការអភិវឌ្ឍយ៉ាងឆាប់រហ័សលើគ្រប់វិស័យ ទន្ទឹមនឹងស្ថានភាពដ៏កាន់តែល្អនៅក្រោយការបោះឆ្នោតសកលឆ្នាំ២០១៨ សកម្មភាពវិនិយោគបានកើនឡើងយ៉ាងគំហុកលើសពីពេលមុនៗ ជាពិសេសវិស័យសំណង់ នេះជាប្រការជះឥទ្ធិពលឱ្យការប្រើប្រាស់ថាមពលអគ្គិសនីនៅឆ្នាំ២០១៩ និងឆ្នាំបន្តបន្ទាប់ទៅមុខទៀតអាចនឹងកើនឡើងលើសពីការគ្រោងទុក។ ចំពោះស្ថានភាពជាក់ស្តែងថ្មីនេះ ដើម្បីឱ្យការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅកម្ពុជាមានសុវត្ថិភាពនិងបរិមាណគ្រប់គ្រាន់ រាជរដ្ឋាភិបាលបានធ្វើការព្យាករណ៍សេចក្តីត្រូវការថាមពលអគ្គិសនីឡើងវិញយ៉ាងប្រុងប្រយ័ត្ន និងរកប្រភពថាមពលអគ្គិសនីបន្ថែមឱ្យបានគ្រប់គ្រាន់ទាន់តាមកំណើនតម្រូវការ ព្រមទាំងរៀបចំអភិវឌ្ឍប្រព័ន្ធបណ្តាញចែកចាយអគ្គិសនីគ្រប់រូបភាពទូទាំងប្រទេស។ ដូចបណ្តាប្រទេសនានាមួយចំនួនក្នុងតំបន់ដែរ ក្រៅពីការអភិវឌ្ឍប្រភពថាមពលអគ្គិសនីក្នុងស្រុក ប្រទេសកម្ពុជាត្រូវការនាំចូលថាមពលអគ្គិសនីបន្ថែមទៀតពីប្រទេសជិតខាង។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាលបានតម្រង់ទិសជាអាទិភាពទៅរកប្រទេសឡាវដែលជា ម្យ៉ាងទៀត ការនាំចូលថាមពលអគ្គិសនីពីប្រទេសឡាវ មានលក្ខណៈអនុគ្រោះទាំងថ្លៃ ទាំងបរិមាណ និងលក្ខខណ្ឌទិញលក់ល្អប្រសើរ ហើយមានសុវត្ថិភាពយូរអង្វែង។

រាជរដ្ឋាភិបាល បានសម្រេចអនុម័តលើគម្រោងទិញថាមពលអគ្គិសនីផលិតដោយធ្យូងថ្ម ២៤០០ មេហ្គាវ៉ាត់ ពីប្រទេសឡាវ មកពីរោងចក្រចំនួនពីរកន្លែង ដែលត្រូវផ្គត់ផ្គង់ថាមពលអគ្គិសនីផ្ទាល់មុខមកកម្ពុជាតែមួយគត់ ដោយភ្ជាប់ផ្ទាល់មកប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់កម្ពុជា។ គម្រោងវិនិយោគនេះមានទំហំទុនសរុបចំនួន ៥៩៧០លានដុល្លារអាមេរិក និងមានអាណត្តិនៃកិច្ចព្រមព្រៀងទិញលក់អគ្គិសនីរយៈពេល៣០ឆ្នាំ។ ចំពោះអានុភាព ក្រុមហ៊ុន TSBP SEKONG POWER AND MINERAL COMPANY LIMITED អាចបញ្ចេញបានចំនួន ៦០០មេហ្គាវ៉ាត់ និងក្រុមហ៊ុន XEKONG THERMAL POWER PLANT COMPANY LIMITED អាចបញ្ចេញបានចំនួន ១៨០០មេហ្គាវ៉ាត់។ ក្រុមហ៊ុនទាំងពីរខាងលើនេះ ទទួលបានសម្បទានធ្វើការអភិវឌ្ឍអណ្តូងរ៉ែធ្យូងថ្ម និងរោងចក្រផលិតអគ្គិសនីពីរដ្ឋាភិបាលប្រទេសឡាវ។

គម្រោងនេះផ្តល់អត្ថប្រយោជន៍ចំពោះប្រទេសកម្ពុជា ដូចជា៖ ទី១)-ទទួលបានថ្លៃអគ្គិសនី ៧,៧សេនដុល្លារអាមេរិកក្នុងមួយគីឡូវ៉ាត់ម៉ោង ជាថ្លៃទាបធៀបនឹងបណ្តារោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មផ្សេងទៀតនៅកម្ពុជា និងមានថ្លៃថេរ ហើយថ្លៃនេះបានឆ្លើយតបនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបញ្ចុះថ្លៃភ្លើងនាពេលអនាគត ទី២)-ទទួលបានលក្ខខណ្ឌបច្ចេកទេសនិងសេដ្ឋកិច្ចនៃកិច្ចព្រមព្រៀងទាំងពីរមានលក្ខណៈប្រសើរជាងកិច្ចព្រមព្រៀងដែលធ្លាប់មានកន្លងមក ទី៣)-ជួយកាត់បន្ថយការទិញថាមពលអគ្គិសនីដែលមានថ្លៃខ្ពស់នាំចូលមកពីប្រទេសវៀតណាមនិងប្រទេសថៃនាពេលបច្ចុប្បន្ន ទី៤)-ធានាបានការផ្គត់ផ្គង់ថាមពលបន្ថែមដល់ប្រព័ន្ធអគ្គិសនីជាតិឲ្យមានស្ថិរភាព ជាពិសេសនៅរដូវប្រាំង ទី៥)-នាំមកនូវចំណេះដឹងនិងការបណ្តុះបណ្តាលបង្កើនសមត្ថភាពជំនាញរបស់កម្មករនិយោជិតអគ្គិសនីកម្ពុជា តាមរយៈការសិក្សានៅរោងចក្រអគ្គិសនីផ្ទាល់ ទី៦)-ផ្តល់លទ្ធភាពឲ្យរាជរដ្ឋាភិបាលកម្ពុជាវិនិយោគសាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ៥០០គីឡូវ៉ុលថ្មីបន្ថែមទៀត ដែលអនុញ្ញាតឲ្យប្រទេសកម្ពុជាអាចទិញថាមពលដែលមានថ្លៃទាបសមរម្យពីបណ្តុំស្ថានីយវារីអគ្គិសនីនៅភាគខាងត្បូងនៃប្រទេសឡាវ និង ទី៧)-មិនមានផលប៉ះពាល់បរិស្ថាននៅក្នុងប្រទេសកម្ពុជា។

**២-បញ្ហាផ្សេងៗ៖**

២.១. អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានអនុម័តបញ្ជូន ១).-កិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ២).-កិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការបង្កើតសម្ព័ន្ធភាពថាមពលព្រះអាទិត្យអន្តរជាតិ ទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។

២.២. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងថា៖

- រាជរដ្ឋាភិបាលបានសម្រេចបញ្ចេញអង្ករចំនួន១.០០០តោន និងថវិកាចំនួន២.០០០លានរៀល ជូនដល់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីត្រៀមជួយសង្គ្រោះដល់ប្រជាពលរដ្ឋនៅតាមបណ្តាខេត្តទាំងឡាយដែលប្រឈមនឹងគ្រោះទឹកជំនន់។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវសហការជាមួយកាកបាទក្រហមកម្ពុជា ក្នុងការនាំយកអង្ករនិងសម្ភារៈប្រើប្រាស់ផ្សេងៗ ដើម្បីចែកជូនប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់។

- រាជរដ្ឋាភិបាលបានណែនាំដល់ក្រសួងស្ថាប័ន និងរដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់នៃបណ្តាខេត្តនានាដែលស្ថិតតាមដងទន្លេ ពិសេសខេត្តស្ទឹងត្រែង ក្រចេះ និងកំពង់ចាម ដែលកម្ពស់ទឹកកំពុងលើសកម្រិតប្រកាសអាសន្ន ព្រមទាំងទឹកជំនន់ដោយទឹកភ្លៀងនៅខេត្តព្រះវិហារ និងខេត្តកំពង់ធំ ត្រូវបង្កើនការប្រុងប្រយ័ត្នខ្ពស់ចំពោះបញ្ហាការបាក់ច្រាំង ខ្យល់កន្ត្រាក់ និងហានិភ័យនានាដែលអាចនឹងកើតឡើង ហើយត្រូវត្រៀមជម្លៀសប្រជាពលរដ្ឋឱ្យបានទាន់វេលាទៅកាន់ទីទួលមានសុវត្ថិភាព និងត្រូវយកចិត្តទុកដាក់ខ្ពស់លើបញ្ហាអនាម័យ ទឹកស្អាត និងសត្វអសិរពិស ក្នុងរដូវកាលទឹកជំនន់។

- រាជរដ្ឋាភិបាលបានណែនាំដល់ក្រសួងស្ថាប័ន និងរដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ត្រូវសហការត្រៀមផ្តល់ស្រូវពូជជូនដល់ប្រជាកសិករនៅតាមបណ្តាខេត្តនានា ដែលបានដាំដុះស្រូវវស្សាហើយទទួលរងការខូចខាតដោយគ្រោះទឹកជំនន់។

- ចំណូលដែលបានមកពីវិស័យប្រេង នឹងត្រូវប្រើប្រាស់សម្រាប់តែការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីអភិវឌ្ឍជាតិតែប៉ុណ្ណោះ ដោយមិនត្រូវយកមកប្រើសម្រាប់ចំណាយចរន្តនោះឡើយ។

- ក្រសួងសាធារណការនិងដឹកជញ្ជូន បាននឹងកំពុងសហការយ៉ាងសកម្មជាមួយរដ្ឋបាលផែនដីក្នុងប្រតិបត្តិការទាញយកចេញសាឡង់ដឹកខ្សាច់មួយគ្រឿងដែលបានបើកបុកសសរស្ពានព្រែកតាមាក់ កាលពីថ្ងៃអាទិត្យទី៨ ខែកញ្ញា ឆ្នាំ២០១៩ ដើម្បីជៀសវាងផលប៉ះពាល់ដល់ស្ពាន ក៏ដូចជាសុវត្ថិភាពនៃការធ្វើដំណើររបស់ប្រជាពលរដ្ឋ។

- ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ឆ្នាំកុរ ព.ស.២៥៦៣ នេះ រាជរដ្ឋាភិបាលបានសម្រេចបើកប្រាក់បៀវត្សសម្រាប់ខែកញ្ញាសរុបតែមួយលើក ព្រមទាំងផ្តល់ប្រាក់ឧបត្ថម្ភចំនួន៥ម៉ឺនរៀលក្នុងម្នាក់ ជូនដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងមន្ត្រីចូលនិវត្តន៍ ក្នុងសប្តាហ៍ទីពីរនៃខែកញ្ញា។

- រាជរដ្ឋាភិបាលតាមរយៈសាលារាជធានីភ្នំពេញ បានសម្រេចបញ្ចេញរថយន្តក្រុងសាធារណៈរបស់សាលារាជធានីភ្នំពេញ ចំនួន១២០គ្រឿង ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ដើម្បីដឹកជញ្ជូនប្រជាពលរដ្ឋធ្វើដំណើរពីរាជធានីភ្នំពេញទៅស្រុកកំណើតតាមបណ្តាខេត្តនានា ដើម្បីជួបជុំបងប្អូន ក្រុមគ្រួសារ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ដោយមិនគិតកម្រៃសេវា ។

- រាជរដ្ឋាភិបាល បានសម្រេចឱ្យរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង រាជធានីភ្នំពេញ បន្តផ្តល់សេវាដឹកជញ្ជូនតាមរថយន្តក្រុង (City Bus) និងកាណូតសាធារណៈ (Taxi Boat) ដោយឥតគិតថ្លៃ រយៈពេល២ឆ្នាំបន្ថែមទៀត ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៩ ដល់ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ ជូនដល់ព្រះសង្ឃ ចាស់ជរា ជនពិការ កុមារ សិស្ស និស្សិត កីឡាករ និងកម្មករ កម្មការិនី។

- រាជរដ្ឋាភិបាលបានត្រៀម iPad ចំនួន៨៩៣គ្រឿង ដើម្បីប្រគល់ជូនដល់សិស្សានុសិស្សដែលបានប្រឡងជាប់និទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នាសម័យប្រឡងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ កន្លងមក។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១០និង៨នាទី។

ថ្ងៃពុធ ១៣កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩